# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតវិទ្យាស្ថានប្រវត្តិសាស្រ្តយោធា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៨ ស្តីពីការបង្កើតអគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា ១**: ត្រូវបានបង្កើតវិទ្យាស្ថានប្រវត្តិសាស្រ្តយោធា ដាក់ចំណុះផ្ទាល់អគ្គនាយកដ្ឋាននយោបាយនិងកិច្ចការបរទេសក្រសួងការពារជាតិ។

**មាត្រា ២**: វិទ្យាស្ថានប្រវត្តិសាស្ត្រយោធាមានតួនាទីធ្វើជាសេនាធិការជូនអគ្គនាយកដ្ឋាននយោបាយនិងកិច្ចការបរទេសលើការងារសិក្សាស្រាវជ្រាវទាក់ទងនឹងប្រវត្តិសាស្ត្រយោធាក្នុងវិស័យការពារជាតិនិងមានភារកិច្ចដូចខាងក្រោម៖

- ទំនាក់ទំនងជាមួយស្ថាប័នក្នុងនិងក្រៅកងទ័ព ដើម្បីសិក្សាស្រាវជ្រាវ ចងក្រងឯកសារទាក់ទងនឹងប្រវត្តិសាស្ត្រ យុទ្ធសាស្ត្រ យុទ្ធវិធីរបស់កងទ័ពទាំងបីប្រភេទ និងទ័ពជំនាញនីមួយៗ ដែលបានជួបនឹងស្ថានការណ៍ជាក់ស្តែង តាមជំនាន់ និងពេលវេលាកន្លងមក។
- សហការជាមួយកងទ័ពប្រទេសជាមិត្តនិងប្រជាជន ធ្វើការសិក្សាស្រាវជ្រាវនិងផ្លាស់ប្តូរបទពិសោធន៍នូវវិធីសាស្ត្រក្នុងការចងក្រងឯកសារដែលពាក់ព័ន្ធប្រវត្តិសាស្ត្រកងទ័ព។
- ធ្វើការសិក្សា និងវិភាគព័ត៌មានផ្សេងៗដែលទាក់ទងនឹងប្រវត្តិរបស់កងទ័ព ឲ្យបានត្រឹមត្រូវ និងសុក្រឹត។
- ទំនាក់ទំនងជាមួយបណ្តាឥស្សរជនជើងចាស់នានា ដើម្បីសិក្សាស្វែងយល់ពីប្រវត្តិសាស្ត្ររបស់កងទ័ព តាមសម័យកាលនីមួយៗ។
- រក្សាទុកនូវរាល់ឯកសារដែលបានស្រាវជ្រាវ ចងក្រង និងរក្សាទុកឲ្យបានគត់មត់ ត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងបានយូរអង្វែង។
- អប់រំ និងលើកកម្ពស់នូវវិន័យ អត្តចរិត សីលធម៌របស់យោធិននៅក្នុងវិទ្យាស្ថានប្រវត្តិសាស្ត្រយោធា ដើម្បីពង្រីកកិត្យានុភាពរបស់កងយោធពលខេមរភូមិន្ទ។
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់លើប្រគល់ឲ្យ។

វិទ្យាស្ថានប្រវត្តិសាស្ត្រយោធាមានឋានៈស្មើនឹងនាយកដ្ឋាន និងដឹកនាំដោយនាយក០១រូប អមដោយនាយករង ០៣រូបជាជំនួយការ។

**មាត្រា ៣**: វិទ្យាស្ថានប្រវត្តិសាស្ត្រយោធា មានរចនាសម្ព័ន្ធចាត់តាំងដូចខាងក្រោម៖

- នាយក
- នាយករង
- ផ្នែកបុគ្គលិក
- ផ្នែកហិរញ្ញវត្ថុ
- លេខាធិការដ្ឋាន
- ការិយាល័យប្រវត្តិសាស្ត្រយោធាកម្ពុជា និងសង្គ្រាមប្រជាជន
- ការិយាល័យប្រវត្តិសាស្ត្រ កិច្ចសហប្រតិបត្តិការជាមួយកងទ័ពអន្តរជាតិ និងសន្តិសុខតំបន់
- ការិយាល័យហ្វឹកហ្វឺន, វិធីសាស្ត្រ, វាយតម្លៃ និងបោះពុម្ព
- ការិយាល័យប្រវត្តិសាស្ត្រយុទ្ធសាស្ត្រ, សិក្សាយុទ្ធនាការ និងយុទ្ធវិធី

ការរៀបចំរចនាសម្ព័ន្ធ ក្របខ័ណ្ឌចាត់តាំង និងតួនាទី ភារកិច្ចការិយាល័យនីមួយៗរបស់វិទ្យាស្ថានប្រវត្តិសាស្ត្រយោធា អាស្រ័យដោយក្រសួងការពារជាតិកំណត់។

**មាត្រា ៤**: បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

**<u>កន្លែងទទួល</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

សច្ចាប័នៈ ថ្ងៃទី២១ ខែ កញ្ញា ឆ្នាំ២០១២
**បានឃើញ និងឯកភាព**
លើរចនាសម្ព័ន្ធចាត់តាំងរបស់វិទ្យាស្ថានប្រវត្តិសាស្ត្រយោធា
នៃអគ្គនាយកដ្ឋាននយោបាយនិងកិច្ចការបរទេស
នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# រចនាសម្ព័ន្ធចាត់តាំង
# វិទ្យាស្ថានប្រវត្តិសាស្ត្រយោធា
# នៃអគ្គនាយកដ្ឋាននយោបាយនិងកិច្ចការបរទេស
# ចំនួនរួម ៤៨នាក់

